UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៨

# សេចក្តីថ្លែងការណ៍ជាសាធារណៈ:

## ការសម្លាប់លោកឃឹម សម្បូរណ៏ អ្នកសារព័ត៌មាន និងកូនប្រុសរបស់លោក កាលពីថ្ងៃទី១១ កក្កដា ២០០៨

ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សូមសំដែងនូវការព្រួយបារម្ភ និងទុក្ខក្រៀមក្រំរបស់ខ្លួន ចំពោះការសម្លាប់លោកឃឹម សម្បូរណ៏ និងកូនប្រុសរបស់លោកឈ្មោះខាត់ សារិនភាតា កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨ នៅកណ្តាលទីក្រុងភ្នំពេញ។ ការិយាល័យ សូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារជនរងគ្រោះ មិត្តភ័ក្ត្រ និងសហការីរបស់ជនរងគ្រោះ និងសូមចូលរួមមរណៈទុក្ខយ៉ាងក្រៀមក្រំជាមួយពួកគេទាំងអស់គ្នា។

ខណៈពេលដែលធ្វើការសំរេចចិត្តឆាប់ពេក ថាតើឃាតកម្មនេះ ទាក់ទងទៅនឹងអត្ថបទនានាដែលលោកបានសរសេរឬក៏អត់នោះ មានការចង្អុលបង្ហាញពីបរិបទមួយចំនួនដែលស្នើឡើងថាវាអាចជាដើមចមនៃការសម្លាប់នេះ ។ លោកឃឹម សម្បូរណ៏ គឺជាអ្នកកាសែតដើងចាស់ម្នាក់ធ្វើការឱ្យកាសែតមនសិការខ្មែរ ដែលមាននិន្នាការជាមួយគណៈបក្សប្រឆាំងសម រង្ស៊ី។ នៅក្នុងប៉ុន្មានសប្តាហ៏មុនការបាញ់សម្លាប់នេះ លោកបានសរសេរអត្ថបទជាច្រើន រិះគន់គណៈបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។ កាសែតនេះ មានប្រវត្តិយូរអង្វែងមកហើយពីវិវាទជាមួយរដ្ឋាភិបាល ដោយសារតែអត្ថបទរិះគន់របស់ខ្លួន។ កាសែតនេះត្រូវបានបិទមិនឱ្យចេញផ្សាយអស់រយៈពេល១ខែ កាលពីឆ្នាំ២០០២ ក្រោយពីបោះពុម្ពផ្សាយអត្ថបទរិះគន់មួយចំនួន និងត្រូវពិន័យជាប្រាក់ចំនួន ៤៥០០ដុល្លាអាមេរិច កាលពីឆ្នាំ២០០៦ ដោយសារតែបានចោទប្រកាន់រដ្ឋមន្ត្រីម្នាក់របស់រដ្ឋាភិបាលពីបទពុករលួយ ។ **មនសិការខ្មែរ** គឺជាកាសែតដែលនៅសល់ចុងក្រោយសំខាន់ជាងគេដែលមាននិន្នាការជាមួយគណបក្សសម រង្ស៊ី។ កាលពីខែមិថុនា ឆ្នាំ ២០០៨ និពន្ធនាយកកាសែតនេះ លោកដាំ សិទ្ធ ត្រូវបានឃុំខ្លួនអស់រយៈពេលមួយសប្តាហ៏ ដោយសារតែការចោទប្រកាន់ ក្នុងការពាក់ព័ន្ធពីបទរាយការណ៏ប្រសាសន៍ដ៏ចំរូងចំរាស់

10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

របស់លោកសម រង្ស៊ី និងវិធានការច្បាប់បន្ទាប់មកទៀត ប្រឆាំងលោក ដាំ សិទ្ធ ដោយរដ្ឋមន្ត្រីម្នាក់។

ដោយមិនគិតដល់មូលហេតុនៃឃាតកម្មនេះ អំពើនេះបានជះឥទ្ធិពលចៀសមិនផុត ដល់ការយល់ឃើញជាសាធារណៈ ធ្វើឱ្យភាពភ័យខ្លាចពីនយោបាយរស់ឡើងវិញនៅក្នុងសតិអារម្មណ៍របស់ប្រជាជន ។ ហេតុដូច្នេះ នេះគឺជាការសំខាន់ណាស់ដែលអាជ្ញាធររបស់រដ្ឋាភិបាលត្រូវធ្វើការស៊ើបអង្កេត ឱ្យបានឆាប់រហ័ស ពេញលេញ និងគួរឱ្យជឿបាន ហើយនាំខ្លួនជនទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋបានសំរេចនេះ ទៅតុលាការព្រមទាំងជម្រះមន្ទិលសង្ស័យពីមូលហេតុនៃឃាតកម្មនេះ។ នេះគឺជាការធានាមួយល្អជាងអ្វីៗទាំងអស់ នៅក្នុងបរិបទនៃនីទណ្ឌភាពដែលនៅតែបន្ត ចំពោះការសម្លាប់អ្នកសារព័ត៌មាន កាលពីអតីតកាល ជាមួយនឹងផ្ទុក់អារម្មណ៍ថា ជនល្មើសស្ថិតនៅពីលើច្បាប់ ហើយអ្នកសារព័ត៌មានមិនត្រូវបានច្បាប់ការពារនោះ។

ការសម្លាប់អ្នកសារព័ត៌មានរូបណាក៏ដោយ គឺជាការរំលោភសិទ្ធិជាមូលដ្ឋានដល់សេរីភាពនៃការបញ្ចេញមតិ ។ ឃាតកម្មនៅក្នុងរយៈពេលនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ២៧ កក្កដា ២០០៨នេះ ជះស្រមោលដល់យុទ្ធនាការឃោសនាបោះឆ្នោតដែលរហូតមកដល់ពេលមុននេះបានប្រព្រឹត្តទៅយ៉ាងទូលំទូលាយដោយគ្មានអំពើហឹង្សាធ្ងន់ធ្ងរបើធ្វើការកត់សំគាល់ជាមួយនឹងការបោះឆ្នោតកាលពីលើកមុន។ តែឃាតកម្មនេះ កំពុងតែបំផ្លាញ មិនត្រឹមតែគ្រួសារជនរងគ្រោះ មិត្តភ័ក្ត្រ និងសហការីរបស់ជនរងគ្រោះនោះទេ តែក៏បានបំផ្លាញដល់កាសែតនេះផ្ទាល់ សហគមន៍អ្នកសារព័ត៌មាន និងសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ព្រមទាំងបំផ្លាញដល់ការចូលរួមជាធម្មានុរូបរបស់គណៈបក្សប្រឆាំងនៅកម្ពុជាទៀតផង។

ការិយាល័យឧត្តមស្នងការ កត់សំគាល់ក្នុងឆ្នាំថ្មីៗនេះថា កំរិតនៃអំពើហឹង្សាប្រឆំងចំពោះអ្នកសារព័ត៌មាន មានការថយចុះគួរឱ្យកត់សំគាល់ បើប្រៀបធៀបទៅនឹងទសវត្សរ៍ឆាំ ៩០។ វិវាទជាមួយអ្នកសារព័ត៌មាន ត្រូវបានដោះស្រាយតាមផ្លូវតុលាការ កាន់តែមានការកើនឡើង តែគួរឱ្យសោកស្តាយដែល ចំណាត់ការតាមព្រហ្មទណ្ឌនៅតែបន្ត ជាជាងតាមការទាមទារតាមផ្លូវរដ្ឋប្បវេណី ចំពោះការខូចខាត។ ឃាតកម្មនេះ ធ្វើឱ្យភាពភ័យខ្លាចដែលអ្នកសារព័ត៌មានអាចក្លាយជាផ្ទាំងស៊ីបម្តងទៀតនៃការបាញ់សម្លាប់រស់ឡើងវិញ។

វាសំខាន់ណាស់សំរាប់ការអនុវត្តន៍សិទ្ធិមានសេរីភាពបញ្ចេញមតិតាមរដ្ឋធម្មនុញ្ញដែលអាជ្ញាធរត្រូវខិតខំប្រឹងប្រែងជាថ្មីផងដែរដើម្បីការពារអ្នកសារព័ត៌មានពីអំពើហឹង្សា ហើយត្រូវដឹងថាករណីបរិហាកេរ្តិ៍ ត្រូវដោះស្រាយតាមបណ្តឹងរដ្ឋប្បវេណី ជាជាងតាមបណ្តឹងព្រហ្មទណ្ឌ ។ សេរីភាពសំដែងទស្សនៈរបស់នរណាម្នាក់ដោយសន្តិវិធី និងសេរីភាពចូលរួមក្នុងការពិភាក្សា

សាធារណៈស្តីពីបញ្ហាកង្វល់មួយចំនួននៅក្នុងសង្គម គឺជាលក្ខខណ្ឌគន្លឹះសំរាប់ការអភិវឌ្ឍន៍បរិដ្ឋានលទ្ធិប្រជាធិបតេយ្យមួយ។

ការិយាល័យប្រចាំនៅកម្ពុជា នៃឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ត្រៀមខ្លួនជាស្រេចដើម្បីស្វែងរកជាមួយក្រសួងព័ត៌មាន និងស្ថាប័នពាក់ព័ន្ធដទៃទៀត ព្រមទាំងតួអង្គដែលមានប្រយោជន៍ផ្សេងទៀត ថាត្រូវធ្វើយ៉ាងដូចម្តេចទើបការិយាល័យអាចរួមចំណែកពង្រឹង លើកស្ទួយ និងការពារការអនុវត្តន៍ដោយសន្តិវិធីនូវសិទ្ធិមានសេរីភាពក្នុងការសំដែងមតិ និងសារព័ត៌មានដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

<u>**មូលដ្ឋានព័ត៌មាន:**</u> **និទណ្ឌភាពចំពោះការសម្លាប់ និងការប៉ុនប៉ងសម្លាប់អ្នកសារព័ត៌មានពីអតីតកាល :**
ការសម្លាប់លោក ឃឹម សម្បូរណ៍ ប្រព្រឹត្តតាមឃាតកម្មប្រហាក់ប្រហែលគ្នាចំនួនប្រាំបី និងការប៉ុនប៉ងធ្វើឃាតអ្នកសារព័ត៌មាន នៅកម្ពុជាតាំងពីឆ្នាំ១៩៩៤ ដែលនៅក្នុងរឿងក្តីទាំងអស់នេះជនល្មើសនៅតែបន្តសប្បាយជាមួយនឹងនិទណ្ឌភាព។ រឿងក្តីទាំងនោះរួមមាន:

- លោកនួន ចាន់ និពន្ធនាយកកាសែតសំលេងយុវជនខ្មែរ ត្រូវបានបាញ់សម្លាប់ដោយជនពីរនាក់ជិះម៉ូតូមួយគ្រឿង នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី៧ កញ្ញា ១៩៩៤។
- លោកសៅ ចាន់តារា អ្នកសារព័ត៌មានកោះសន្តិភាព ត្រូវបានបាញ់សម្លាប់កាលពីថ្ងៃទី០៨ ធ្នូ ១៩៩៤ នៅខេត្តកំពង់ចាម។ មន្ត្រីយោធាម្នាក់ ត្រូវបានកាត់ទោសពីករណីឃាតកម្មនេះ តែត្រូវបានលើកលែងចោទឱ្យរួចខ្លួន។ សាលាឧទ្ធរណ៍ក៏បានសម្រេចតំកល់សេចក្តីសម្រេចឱ្យរួចខ្លួននេះ ហើយបណ្តឹងសារទុក្ខមិនត្រូវបានធ្វើទៅតុលាការកំពូលទេ ។
- លោកឯក មង្គល អ្នកសារព័ត៌មានឱ្យវិទ្យុអេហ្វអឹម៩០ បានទទួលរងនូវការបាញ់ប្រហារដោយអាវុធជាច្រើនគ្រាប់ នៅពេលដែលលោកបើកបរនៅតាមផ្លូវ នៅកណ្តាលទីក្រុងភ្នំពេញ កាលពីថ្ងៃទី២១ តុលា ១៩៩៥។ លោកបានរួចជីវិតពីការវាយប្រហារនេះ។
- លោកធន់ ប៊ុនលី និពន្ធនាយកកាសែតឧត្តមគតិខ្មែរ ត្រូវបានបាញ់សម្លាប់ដោយជនពីរនាក់ជិះម៉ូតូមួយគ្រឿង នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៨ ឧសភា ១៩៩៦ ។ កន្លះម៉ោងមុនស្លាប់ លោកបានប្រាប់មិត្តភក្តិម្នាក់របស់លោកថា លោកភ័យខ្លាចចំពោះសុវត្ថិភាពរបស់លោក។ នៅឆ្នាំ១៩៩៥ លោកត្រូវបានគេចោទប្រកាន់ និងផ្តន្ទាទោសចំនួនពីរដង ពីបទចុះផ្សាយអត្ថបទជាច្រើនដែលរិះគន់ដល់រាជរដ្ឋាភិបាល ។
- លោកឡេង សំអាង និពន្ធនាយកកាសែតគំនិតកូនខ្មែរ ត្រូវបានវាយដំ និងបាញ់ប្រហារដោយនគរបាល កាលពីថ្ងៃទី២ មករា ១៩៩៧។ លោកបានរួចជីវិតពីការវាយប្រហារនេះ។

- លោកមៃឃើល សិននៀរ (Michael Senior) អ្នកថតរូបសេរី មានដើមកំណើតជាខ្មែរ ត្រូវបានបាញ់សម្លាប់ដោយទាហាន នៅពេលដែលលោកមានបំណងថតរូបទាហានជាច្រើននាក់ដែលកំពុងលួចទំនិញនៅក្នុងផ្សារមួយនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី៨ កក្កដា ១៩៩៧ ។
- លោកថុង អ៊ុយប៉ាង និពន្ធនាយកកាសែតកោះសន្តិភាព ត្រូវបានបាញ់ប្រហារ នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី៨ មិថុនា ១៩៩៨ តែបានរួចជីវិតពីការរងរបួសនោះ។ ឆ្នាំមុន គ្រាប់បែកពីរគ្រាប់ត្រូវបានគេបោះចូលទៅក្នុងស្នាក់ការកាសែតនេះ។
- លោកជួរ ជេតថារិទ្ធិ៍ អ្នកសារព័ត៌មានឱ្យវិទ្យុតាព្រហ្ម ត្រូវបានបាញ់សម្លាប់ដោយជនពីរនាក់ជិះម៉ូតូមួយគ្រឿង នៅពេលដែលលោក មកដល់កន្លែងធ្វើការរបស់លោក កាលពីថ្ងៃទី១៨ តុលា ២០០៣ ។

ក្នុងពេលជាមួយគ្នានេះដែរ អ្នកសារព័ត៌មានបីរូបទៀត បានទទួលមរណៈភាព ដោយសារតែអំពើហឹង្សា នៅក្នុងកាលៈទេសៈដែលមិនទាន់ត្រូវបានដោះស្រាយនៅឡើយ (លោកធូរ ចាន់មង្គល និពន្ធនាយកកាសែតអន្តរាគមន៍ ស្លាប់កាលពីថ្ងៃទី១១ មិថុនា ១៩៩៤ លោកពេជ្រ ឯម អ្នកបច្ចេកទេសទូរទស្សន៍ជាតិកម្ពុជានៅក្រុងព្រះសីហនុ ស្លាប់កាលពីថ្ងៃទី៥ ឧសភា ១៩៩៧ និងលោកអ៊ូ សារឿន អ្នកយកព័ត៌មានឱ្យកាសែតសំលេងរាស្ត្រខ្មែរ)។ អ្នកសារព័ត៌មាន នៅតែប្រឈមមុខជារឿយៗនឹងការគំរាមកំហែង រួមទាំងការគំរាមកំហែងដល់អាយុជីវិតទៀតផង ដែលជារឿយៗតំរូវឱ្យពួកគេលាក់ខ្លួនពួនអាត្មា ឬសុំសិទ្ធិជ្រកកោននយោបាយ។

លោកតំណាងពិសេសជាបន្តបន្ទាប់ របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានយល់ស្របនៅក្នុងការវិភាគរបស់ពួកគេថា និទណ្ឌភាព គឺជាឧបសគ្គសំខាន់ចំបងតែមួយគត់បំផ្លាញដល់ប្រព័ន្ធនីតិរដ្ឋនៅកម្ពុជា។ នៅក្នុងភាគច្រើននៃរឿងក្តីដែលអ្នកសារព័ត៌មានត្រូវបានសម្លាប់ អាជ្ញាធរតែងបានគូសបញ្ជាក់ថា ការស៊ើបអង្កេតកំពុងតែបន្តធ្វើ ហើយមិនទាន់ឬមានការរីកចំរើនតិចតួចពីការស៊ើបអង្កេតរហូតមកដល់ពេលនេះ ហើយតាមដែលការិយាល័យដឹង គ្មានជនល្មើសណាម្នាក់ត្រូវបាននាំខ្លួនទៅតុលាការ ដើម្បីផ្តន្ទាទោសពីបទឧក្រិដ្ឋទាំងនេះទេ។